# នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង
# នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

## ព័ត៌មានពិស្តារអំពីការដាក់ឯកសារ

សំណុំរឿងលេខ៖ ០០២/១៩-០៩-២០០៧-អវតក/អជសដ

ភាគីដាក់ឯកសារ៖ លោក **ខៀវ សំផន**

ដាក់ជូន៖ អង្គជំនុំជម្រះសាលាដំបូង

ភាសាដើម៖ **បារាំង**

កាលបរិច្ឆេទឯកសារ៖ ថ្ងៃទី ៣០ ខែ ឧសភា ឆ្នាំ ២០១៣

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 30-May-2013, 15:10
CMS/CFO: Sann Rada

## ចំណាត់ថ្នាក់ឯកសារ

ចំណាត់ថ្នាក់ឯកសារស្នើឡើងដោយភាគីដាក់ឯកសារ៖ **សាធារណៈ**

ចំណាត់ថ្នាក់ឯកសារដោយអង្គជំនុំជម្រះសាលាដំបូង៖ **សាធារណៈ/Public**

ប្រភេទនៃចំណាត់ថ្នាក់៖

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់ណ្ដោះអាសន្ន៖

ឈ្មោះមន្ត្រីទទួលបន្ទុកផ្នែកសំណុំរឿង និងឯកសារ៖

ហត្ថលេខា៖

---

# ចម្លើយតបទៅនឹងសំណើរបស់សហព្រះរាជអាជ្ញាដែលបានស្នើសុំឲ្យកោះហៅសាជាថ្មី ដើមបណ្ដឹងរដ្ឋប្បវេណី ស សារិន និងបង្គាប់ឲ្យមានការវាយតម្លៃពីតម្រូវការ របស់រូបលោកទាក់ទងនឹងវិធានការការពារខ្លួន

---

ដាក់ដោយ៖

**មេធាវីការពារក្ដី លោក ខៀវ សំផន**

មេធាវី គង់ សំអុន

មេធាវី Anta GUISSÉ

មេធាវី Arthur VERCKEN

មេធាវី Jacques VERGÈS

ដាក់ជូន៖

**អង្គជំនុំជម្រះសាលាដំបូង៖**

ចៅក្រម និល ណុន

ចៅក្រម Silvia CARTWRIGHT

ចៅក្រម យ៉ូរ ឧត្តរា

ចៅក្រម Jean-Marc LAVERGNE

ចៅក្រម យ៉ា សុខន

**សហព្រះរាជអាជ្ញា៖**

លោកស្រី ជា លាង

លោក Andrew CAYLEY

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់**

**ក្រុមមេធាវីការពារក្តីទាំងអស់**

**ជំនួយការ៖**

លោកស្រី សេង សុជាតា

កញ្ញា Marie CAPOTORTO

កញ្ញា Shéhérazade BOUARFA

កញ្ញា Mathilde CHIFFERT

កញ្ញា Vera MANUELLO

កញ្ញា អ៊ុច ស្រីផាត

លោកស្រី សុគន្ធ មោនីកា

លោក Pierre TOUCHE

កញ្ញា Blandine ZELLER

# គោរពជូនអង្គជំនុំជម្រះសាលាដំបូង

១. នៅថ្ងៃទី ០៩ ខែ មេសា ឆ្នាំ ២០១៣ លោក ស សារិន បានចូលខ្លួននៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង ("អង្គជំនុំជម្រះ") ក្នុងនាមជាដើមបណ្តឹងរដ្ឋប្បវេណី។

២. លោក ស សារិន ត្រូវបានអង្គជំនុំជម្រះកោះហៅឱ្យចូលខ្លួនមកផ្តល់សក្ខីកម្មពាក់ព័ន្ធនឹងអង្គហេតុ ដែលរូបលោកបានជម្រាបដល់អ្នកស៊ើបអង្កេតនៃមជ្ឈមណ្ឌលឯកសារកម្ពុជា នៅអំឡុងនៃកិច្ចសម្ភាសមួយដែលបានធ្វើឡើងកាលពីថ្ងៃទី ០៥ និង ទី ០៦ ខែ ឧសភា ឆ្នាំ ២០០៩[1]។

៣. អង្គហេតុដែល លោក ស សារិន បានរៀបរាប់នៅក្នុងកិច្ចសម្ភាសរបស់លោកជាមួយមជ្ឈមណ្ឌលឯកសារកម្ពុជាពាក់ព័ន្ធនឹងវគ្គអប់រំនយោបាយ ដែលបង្រៀនដោយមេដឹកនាំខ្មែរក្រហមមួយចំនួន ហើយរូបលោកផ្ទាល់ក៏ទំនងជាបានចូលរួមក្នុងវគ្គអប់រំទាំងអស់នោះដែរ[2]។ លោកបានអះអាងថា នៅក្នុងវគ្គអប់រំនយោបាយនោះ លោក នួន ជា និង លោក ខៀវ សំផន ប្រហែលជាបានថ្លែង-ការណ៍ណែនាំឱ្យកម្ទេច "ខ្មាំងផ្ទៃក្នុង និងខ្មាំងខាងក្រៅ"[3]។

៤. នៅក្នុងកិច្ចសម្ភាសជាមួយមជ្ឈមណ្ឌលឯកសារកម្ពុជានេះផងដែរ លោក ស សារិន បាន៖ ១) ផ្តល់ព័ត៌មានពាក់ព័ន្ធនឹងការបញ្ជាឱ្យសម្លាប់អតីតទាហានសាធារណរដ្ឋខ្មែរ ដែលទំនងជាបញ្ជាចេញមកពី"គណៈមជ្ឈិម" នៃបក្សកុម្មុយនីស្តកម្ពុជា[4] និង ២) ព័ត៌មានទាក់ទិននឹងមន្ទីរសន្តិសុខ ដែលត្រូវបានបង្កើតឡើងដើម្បីអនុវត្តនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជា ក្នុងការកម្ទេចខ្មាំងរបស់របបកម្ពុជាប្រជាធិបតេយ្យ[5]។

៥. ក្នុងអំឡុងពេលផ្តល់សក្ខីកម្មនៅសវនាការ នៅពេលដែលសហព្រះរាជអាជ្ញាស្នើសុំឱ្យ លោក ស សារិន ធ្វើការបំភ្លឺពាក់ព័ន្ធនឹងសំដីណែនាំឱ្យសម្លាប់ខ្មាំងដែលលោកដើមបណ្តឹងរដ្ឋប្បវេណីបានអះ

[1] ប្រតិចារឹកនៃកិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ ស សារិន ថ្ងៃទី ០៥ និងទី ០៦ ខែ ឧសភា ឆ្នាំ ២០០៩ ឯកសារ **D230/1.1.874c**។

[2] ដូចយោងខាងលើ។

[3] ដូចយោងខាងលើ។

[4] ដូចយោងខាងលើ។

[5] ដូចយោងខាងលើ។

អាងថាជាសំដីរបស់លោក ខៀវ សំផន នោះ លោក ស សារិន បានសម្តែងពីការព្រួយបារម្ភជាលើកដំបូង ពាក់ព័ន្ធនឹងសុវត្ថិភាពផ្ទាល់ខ្លួនរបស់លោក[6]។

៦. នៅថ្ងៃនោះ លោក ស សារិន បានស្នើឱ្យអង្គជំនុំជម្រះជួយធានាសុវត្ថិភាពរបស់លោក មុននឹងលោកបន្តការធ្វើសក្ខីកម្មរបស់ខ្លួន[7]។ អង្គជំនុំជម្រះបានដកខ្លួនដើម្បីធ្វើការពិភាក្សា ហើយបន្ទាប់មកលោកប្រធានអង្គជំនុំជម្រះបានសួរទៅលោក ស សារិន ថាតើខ្លួនមានបំណងផ្តល់សក្ខីកម្មនៅក្នុងសវនាការអសាធារណៈដែរឬទេ[8]។ លោក ស សារិន បានបដិសេធ ដោយនៅតែទទូចថាលោកនឹងមិនបន្តផ្តល់សក្ខីកម្មរបស់លោកទៀតទេ ល្គឹកណាវិធានការការពារដែលលោកបានស្នើសុំមិនទាន់ត្រូវបានប្រគល់ជូនលោក[9]។ លោក ស សារិន បានបញ្ជាក់ប្រាប់អង្គជំនុំជម្រះថាលោកមានបំណងចង់បានមនុស្សបួននាក់សម្រាប់ការពារសុវត្ថិភាពរបស់លោករហូតដល់ថ្ងៃលោកស្លាប់[10]។

៧. លោកប្រធានអង្គជំនុំជម្រះមិនបានឯកភាពតាមសំណើសុំនេះឡើយ ដោយលោកប្រធានបានគូសបញ្ជាក់ថា "[សំណើសុំបែបនេះ] គឺមិនមានហេតុផលសមស្របទេ"[11]។ លោកប្រធានបានរំលឹកលោក ស សារិន ថា អង្គជំនុំជម្រះមិនមានយន្តការណាមួយដែលអនុញ្ញាតឱ្យផ្តល់ការការពារបែបនេះដល់រូបលោករហូតដល់ពេលដែលលោកស្លាប់ឡើយ[12]។ ដូច្នេះ អង្គជំនុំជម្រះក៏សម្រេចបញ្ចប់ការស្តាប់សក្ខីកម្មដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ[13]។

៨. នៅថ្ងៃទី ២០ ខែ ឧសភា ឆ្នាំ ២០១៣ សហព្រះរាជអាជ្ញាបានដាក់សំណើសុំឱ្យអង្គជំនុំជម្រះកោះហៅលោក ស សារិន មកសាជាថ្មីដើម្បីឱ្យដើមបណ្តឹងរដ្ឋប្បវេណីរូបនេះបញ្ចប់នូវសក្ខីកម្មរបស់ខ្លួន[14]។

---

[6] ប្រតិចារឹកសវនាការ ថ្ងៃទី ២៩ ខែ មេសា ឆ្នាំ ២០១៣ ឯកសារ **E1/185.1** ទំព័រ ៣៨-៣៩ (ភាសាបារាំង)។

[7] ដូចយោងខាងលើ។

[8] ដូចយោងខាងលើ ទំព័រ ៥១-៥២។

[9] ដូចយោងខាងលើ។

[10] ដូចយោងខាងលើ ទំព័រ ៥៤។

[11] ដូចយោងខាងលើ ទំព័រ ៦៣-៦៤។

[12] ដូចយោងខាងលើ។

[13] ដូចយោងខាងលើ។

[14] *សំណើរបស់សហព្រះរាជអាជ្ញាសុំឱ្យកោះហៅដើមបណ្តឹងរដ្ឋប្បវេណី ស សារិន សាជាថ្មី និងបង្គាប់ឱ្យមានការវាយតម្លៃជា* ចម្លើយតបទៅនឹងសំណើរបស់សហព្រះរាជអាជ្ញាដែលបានស្នើសុំឱ្យកោះហៅសាជាថ្មីដើមបណ្តឹងរដ្ឋប្បវេណី ស សារិន និងបង្គាប់ឱ្យមានការវាយតម្លៃពីតម្រូវរបស់រូបលោកទាក់ទងនឹងការវិធានការការពារខ្លួន

៩. ក្នុងគោលបំណងនេះ សហព្រះរាជអាជ្ញាក៏បានស្នើសុំផងដែរឱ្យអង្គជំនុំជម្រះបង្គាប់ឱ្យអង្គភាពគាំពារសាក្សី និងអ្នកជំនាញ ធ្វើការវាយតម្លៃឱ្យបានគ្រប់ជ្រុងជ្រោយមួយ៖ ១) ពីអង្គហេតុដែលធ្វើឱ្យ លោក ស សារិន មានការព្រួយបារម្ភពីសុវត្ថិភាពផ្ទាល់ខ្លួនរបស់លោក និង ២) ពីវិធានការដែលមានដើម្បីបញ្ចៀសនូវហានិភ័យពាក់ព័ន្ធនឹងសុវត្ថិភាពរបស់ដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ[15]។

១០. ដើម្បីគាំទ្រសំណើសុំរបស់ខ្លួន សហព្រះរាជអាជ្ញាបានអះអាងថា ស្របទៅតាមកិច្ចព្រមព្រៀងបន្ថែមស្តីពីសន្តិសុខ និង សុវត្ថិភាព និងសេចក្តីណែនាំអនុវត្តដទៃទៀត[16] អ.វ.ត.ក ត្រូវធានាកិច្ចការពារដល់ជនរងគ្រោះ។

១១. មេធាវីការពារក្តី លោក ខៀវ សំផន សូមប្រឆាំងទៅនឹងសំណើសុំនេះ និងសូមអះអាងថាសំណើរបស់ លោក ស សារិន ស្នើសុំវិធានការសន្តិសុខពិតជាយឺតពេល និងមិនមានសមាមាត្រត្រឹមត្រូវ។

១២. ជាក់ស្តែង យុត្តិសាស្ត្រអន្តរជាតិទាក់ទិននឹងសំណើសុំការការពាររបស់សាក្សី គឺមានភាពច្បាស់លាស់ណាស់៖ ការបារម្ភរបស់សាក្សី គឺមិនគ្រប់គ្រាន់សម្រាប់បញ្ជាក់ពីការជឿជាក់មួយដ៏ពិតប្រាកដថាសាក្សីកំពុងស្ថិតនៅក្នុងស្ថានភាពគ្រោះថ្នាក់ឡើយ[17]។ ទំហំអត្តនោម័តនៃការបារម្ភរបស់សាក្សីមិនមែនជាកត្តាតែមួយគត់ដែលត្រូវពិចារណានោះទេ ហើយការបារម្ភនេះក៏មិនមែនជាកត្តាកំណត់ដាច់ខាតសម្រាប់ការវាយតម្លៃពីតម្រូវការវិធានការការពារនោះដែរ[18]។

---

*ផ្លូវការមួយពីតម្រូវការចាំបាច់សម្រាប់វិធានការការពារ* ចុះថ្ងៃទី ២០ ខែ ឧសភា ឆ្នាំ ២០១៣ ឯកសារ **E286**។

[15] ដូចយោងខាងលើ កថាខណ្ឌ ១។

[16] សូមមើលវិធាន ២៩(១) នៃវិធានផ្ទៃក្នុងរបស់ អ.វ.ត.ក។

[17] សូមមើល *រដ្ឋអាជ្ញា ទល់នឹង* Milutinović *និងអ្នកផ្សេងទៀត Decision on Prosecution Sixth Motion for Protective Measures* រឿងក្តីលេខ IT-05-87-PT ចុះថ្ងៃទី ០១ ខែ មិថុនា ឆ្នាំ ២០០៦ កថាខណ្ឌ ១៩, *រដ្ឋអាជ្ញា ទល់នឹង* Rugambarara, *Decision on the Motion for Protective Measures for Defence Witnesses* រឿងក្តីលេខ ICTR-00-59-I ចុះថ្ងៃទី ០៨ ខែ ឧសភា ឆ្នាំ ២០០៦ កថាខណ្ឌ ៧, *រដ្ឋអាជ្ញា ទល់នឹង* Renzaho, *Decision on the Prosecutor's Motion for Protective Measures for Victims and Witnesses to Crimes Alleged in the Indictment* រឿងក្តីលេខ ICTR-97-31-I ចុះថ្ងៃទី ១៧ ខែ សីហា ឆ្នាំ ២០០៥ កថាខណ្ឌ ១០, *រដ្ឋអាជ្ញា ទល់នឹង* Milosević, *Second Decision on Prosecution Motion for Protective Measures for Sensitive Source Witnesses* រឿងក្តីលេខ IT-02-54-T ចុះថ្ងៃទី ១៨ ខែ មិថុនា ឆ្នាំ ២០០២ កថាខណ្ឌ ៧។

[18] *រដ្ឋអាជ្ញា ទល់នឹង* Sesay *និងអ្នកផ្សេងទៀត Decision on Kallon Defence Motion for Immediate Protective Measures for Witnesses and Victims and for Non-Public Disclosure* រឿងក្តីលេខ SCSL-04-15-T ចុះថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ២០០៧ កថាខណ្ឌ ២៥។

សាក្សីដែលវិធានការការពារត្រូវបានស្នើសុំ ត្រូវបង្ហាញពីការបារម្ភដែលមានសំអាងហេតុត្រឹមត្រូវ និងមានលក្ខណៈសត្យានុម័តសម្រាប់សុវត្ថិភាពផ្ទាល់ខ្លួន ឬក៏សម្រាប់សុវត្ថិភាពគ្រួសាររបស់ពួកគេ[19]។

១៣. ភាគីដែលស្នើសុំវិធានការការពារ ត្រូវផ្តល់ដល់អង្គជំនុំជម្រះនូវរាល់ព័ត៌មានដែលអាចអនុញ្ញាតបង្ហាញដល់អង្គជំនុំជម្រះថាការបារម្ភនោះពិតជាមានមូលហេតុសមស្រប[20]។ យុត្តិសាស្ត្រអន្តរជាតិបានបញ្ជាក់ថាការស្វែងរកភ័ស្តុតាងជាបន្ទុករបស់ភាគីដែលស្នើសុំវិធានការការពារ។ ដូច្នេះ ភាគីដែលស្នើសុំវិធានការការពារត្រូវបង្ហាញថាខ្លួន ឬគ្រួសាររបស់ខ្លួនពិតជាមានហានិភ័យ ប្រសិនបើអត្តសញ្ញាណរបស់គាត់ទើបត្រូវបានស្គាល់ជាសាធារណៈ។ លើសពីនេះទៅទៀត ភាគីដែលស្នើសុំវិធានការការពារត្រូវបង្ហាញឱ្យឃើញថាការបារម្ភនោះជាការបារម្ភលើសពីការបារម្ភជាទូទៅ ឬក៏លើសពីការបារម្ភដែលមាននៅគ្រប់ទីកន្លែង។ ភាគីត្រូវបង្ហាញភ័ស្តុតាងពីលក្ខណៈពិសេសនៃស្ថានភាពរបស់ខ្លួន ដើម្បីអាចឱ្យអង្គជំនុំជម្រះជឿជាក់បានថាការបារម្ភនោះពិតជាមានមូលហេតុសត្យានុម័ត និងទឡ្ហីករណ៍ត្រឹមត្រូវ[21]។ ករណីនៅទីនេះគឺមិនដូចគ្នាទេ ពីព្រោះថានៅពេលឆ្លើយទៅនឹងសំណួររបស់លោកសហព្រះរាជអាជ្ញាអន្តរជាតិ ដែលចង់ដឹងថាតើការបារម្ភនោះផ្អែកលើ

---

[19] សូមមើល *រដ្ឋអាជ្ញា ទល់នឹង Karera, Decision on Defence Motion for Protection of Witnesses* រឿងក្តីលេខ ICTR-01-74-T ចុះថ្ងៃទី ០៩ ខែ កុម្ភៈ ឆ្នាំ ២០០៦ កថាខណ្ឌ ២, *រដ្ឋអាជ្ញា ទល់នឹង Kanyarukiga, Decision on Prosecution Motion for Protective Measures* រឿងក្តីលេខ ICTR-2002-78-1 ចុះថ្ងៃទី ០៣ ខែ មិថុនា ឆ្នាំ ២០០៥ កថាខណ្ឌ ២, *រដ្ឋអាជ្ញា ទល់នឹង Bagosora និងអ្នកផ្សេងទៀត Decision on Ntabakuze Motion for Protection of Witnesses* រឿងក្តីលេខ ICTR-98-41- ចុះថ្ងៃទី ១៥ ខែ មីនា ឆ្នាំ ២០០៤ ទំព័រ ២។

[20] *រដ្ឋអាជ្ញា ទល់នឹង Rugambarara, Decision on the Motion for Protective Measures for Defence Witnesses* រឿងក្តីលេខ ICTR-00-59-I ចុះថ្ងៃទី ០៨ ខែ ឧសភា ឆ្នាំ ២០០៦ កថាខណ្ឌ ៨។

[21] *រដ្ឋអាជ្ញា ទល់នឹង Mrkšić និងអ្នកផ្សេងទៀត Decision on Prosecution's Additional Motion for Protective Measures of Sensitive Witnesses* រឿងក្តីលេខ IT-95-13/1-PT ចុះថ្ងៃទី ២៥ ខែ សីហា ឆ្នាំ ២០០៥ កថាខណ្ឌ ៥, *រដ្ឋអាជ្ញា ទល់នឹង Orić, Decision on Urgent Defence Request for Certification for Appeal of the Trial Chamber's Confidential Decision on Second Defence Motion for Protective Measures for Witnesses D002* រឿងក្តីលេខ IT-03-68-T ចុះថ្ងៃទី ២៨ ខែ កញ្ញា ឆ្នាំ ២០០៥ កថាខណ្ឌ ៣, *រដ្ឋអាជ្ញា ទល់នឹង Milosević, Decision on Trial Related Protective Measures for Witnesses (Bosnia)* រឿងក្តីលេខ IT-02-54-T ចុះថ្ងៃទី ៣០ ខែ កក្កដា ឆ្នាំ ២០០២។

ចម្លើយតបទៅនឹងសំណើរបស់សហព្រះរាជអាជ្ញាដែលបានស្នើសុំឱ្យកោះហៅសាជាថ្មីដើមបណ្តឹងរដ្ឋប្បវេណី ស សារិន និងបង្គាប់ឱ្យមានការវាយតម្លៃពីតម្រូវរបស់រូបលោកទាក់ទងនឹងការវិធានការការពារខ្លួន

ព្រឹត្តិការណ៍ណាមួយជាក់លាក់នោះ លោក ស សារិន បានឆ្លើយថា *"អត់មានអ្នកណាប្រាប់ [លោក]ទេ*[22]"។ បន្ទាប់មកលោកបានបន្តទៀតថា៖ *"[...] នេះជាទស្សនៈរបស់[លោក]*[23]"។

១៤. ដូច្នេះ វាជាការពិតណាស់ដែលសំណើរបស់លោក ស សារិន ធ្វើឡើងក្នុងឱកាសដែលលោកមកធ្វើសក្ខីកម្មកាលពីថ្ងៃទី ២៩ ខែ មេសា ឆ្នាំ ២០១៣ គឺពិតជាមិនគ្រប់គ្រាន់ដើម្បីបង្ហាញពីអត្ថិភាពនៃការបារម្ភមួយដែលសមស្របផ្អែកតាមទស្សនៈសត្យានុម័តឡើយ។

១៥. លើសពីនេះទៅទៀត នៅក្នុងកិច្ចសម្ភាសរបស់លោកជាមួយតំណាងមជ្ឈមណ្ឌលឯកសារកម្ពុជាកាលពីឆ្នាំ ២០០៩ លោក ស សារិន បានផ្តល់នូវព័ត៌មានលម្អិត ហើយដែលព័ត៌មានទាំងនោះបានដាក់បន្ទុកយ៉ាងធ្ងន់ធ្ងរលើសហជនជាប់ចោទនៅក្នុងសំណុំរឿងលេខ ០០២/០១។ ដូច្នេះ លោក ស សារិន បានដឹងជាមុនយ៉ាងច្បាស់នូវប្រធានបទដែលនឹងចោទសួរទៅកាន់រូបលោកក្នុងអំឡុងពេលដែលលោកត្រូវមកផ្តល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះ។ ម្យ៉ាងវិញទៀត ទោះបីជាលោកធ្លាប់បានទំនាក់ទំនងជាច្រើនលើកច្រើនសាជាមួយផ្នែកគាំពារសាក្សី និងអ្នកជំនាញ និងជាមួយសហ-មេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីយ៉ាងណាក៏ដោយ ក៏លោកមិនដែលបានបង្ហាញពីការបារម្ភជាក់លាក់ណាមួយពាក់ព័ន្ធនឹងសុវត្ថិភាពរបស់ខ្លួន ហើយក៏មិនដែលបានស្នើសុំវិធានការការពារណាមួយនៅមុនថ្ងៃដែលលោកត្រូវចូលខ្លួនមកផ្តល់សក្ខីកម្មឡើយ។

១៦. ហេតុដូច្នេះហើយទើបនៅថ្ងៃបង្ហាញខ្លួនចំពោះមុខអង្គសវនាការ នៅពេលដែលលោកដើមបណ្តឹងរដ្ឋប្បវេណីបានសម្តែងការព្រួយបារម្ភរបស់លោកជាលើកដំបូង លោកប្រធានអង្គជំនុំជម្រះបានសួរបញ្ជាក់ថា តើដើមបណ្តឹងរដ្ឋប្បវេណីរូបនេះត្រូវបានជូនដំណឹងជាមុនពីលទ្ធភាពក្នុងការទទួលបានវិធានការការពារដែរឬទេ។ លោក ស សារិន បានទទួលស្គាល់ថាអង្គភាពគាំពារសាក្សី និងអ្នកជំនាញ បានជូនដំណឹងលោកជាមុនពីលទ្ធភាពក្នុងការអនុវត្តវិធានការការពារ ដែលអាចអនុញ្ញាតឱ្យលោកស្ថិតនៅជាអនាមិកក្នុងអំឡុងពេលធ្វើសក្ខីកម្ម ប៉ុន្តែលោកមិនមានបំណងស្នើសុំវិធានការនេះទេ[24]។ ជាមួយគ្នានេះដែរ បន្ទាប់ពី លោក ស សារិន បានថ្លែងពីការព្រួយបារម្ភរបស់លោករួចមក អង្គជំនុំជម្រះបានស្នើសុំឱ្យលោកដើមបណ្តឹងរដ្ឋប្បវេណីផ្តល់សក្ខីកម្មជាអសាធារណៈ ប៉ុន្តែ

---

[22] ប្រតិចារឹកសវនាការ ថ្ងៃទី ២៩ ខែ មេសា ឆ្នាំ ២០១៣ ឯកសារ **E1/185.1.** ទំព័រ ៣៩ (ភាសាបារាំង)។

[23] ដូចយោងខាងលើ។

[24] ប្រតិចារឹកសវនាការ ថ្ងៃទី ២៩ ខែ មេសា ឆ្នាំ ២០១៣ ឯកសារ **E1/185.1.** ទំព័រ ៤៦ (ភាសាបារាំង)។

លោកបានបដិសេធនូវសំណើនេះ[25]។ម្យ៉ាងវិញទៀត វាជាការសំខាន់ផងដែរដែលត្រូវធ្វើការគូស បញ្ជាក់ថា មេធាវីលោក ស សារិន ដែលបានចោទសំណួរ និងជាអ្នកមានឱកាសពិភាក្សាជាមួយ កូនក្ដីរបស់ខ្លួននៅមុនពេលសវនាការនោះ មិនបានបង្ហាញពីការបារម្ភណាមួយទាល់តែសោះរបស់ កូនក្ដីខ្លួននៅមុនការចាប់ផ្ដើមការផ្ដល់សក្ខីកម្មរបស់ដើមបណ្ដឹងរដ្ឋប្បវេណី។ នៅពេលនោះ លោក ស សារិន ខ្លួនឯងផ្ទាល់ក៏មិនបានលើកឡើងពីបញ្ហានេះដែរ។

១៧. តាមរយៈហេតុការណ៍ដែលកើតមានក្នុងអំឡុងពេលសវនាការបែបនេះ វាពិតច្បាស់ណាស់ថារហូត មកទល់ពេលដែលខ្លួនត្រូវបានចោទសួរដោយសហព្រះរាជអាជ្ញាអន្តរជាតិ លោក ស សារិន មិន មានបំណងស្នើសុំវិធានការការពារឡើយ។ ទោះបីថាលោកមានឱកាសច្រើនក្នុងការធ្វើសំណើសុំ បែបនេះក៏ដោយក៏ លោក ស សារិន មិនបានសម្ដែងពីការព្រួយបារម្ភចំពោះសុវត្ថិភាពរបស់ខ្លួន ឡើយ ស្របទៅតាមយុត្តិសាស្ត្រជាធរមានដែលសមស្រប និងមានមូលដ្ឋានច្បាស់លាស់។

១៨. សហមេធាវីការពារក្ដី លោក ខៀវ សំផន យល់ឃើញថាជម្រើសរបស់ លោក ស សារិន ក្នុងការ មិនស្នើសុំវិធានការការពារដែលត្រូវបានប្រគល់ជូនលោកនៅមុនពេលផ្ដល់សក្ខីកម្ម មានន័យថាលោក បានបោះបង់នូវសិទ្ធិទទួលបានវិធានការបែបនេះ។ ដូច្នេះ ល្គឹកណាដែលមិនមានអ្វីមួយដែលអាច អនុញ្ញាតឲ្យយើងសន្និដ្ឋានបានអំពីការផ្លាស់ប្ដូរកាលៈទេសៈ រវាងពេលដែលលោកបានបដិសេធស្នើ សុំវិធានការការពារ និងថ្ងៃដែលលោកត្រូវចូលខ្លួននៅចំពោះមុខអង្គជំនុំជម្រះ សំណើរបស់សហ ព្រះរាជអាជ្ញាសុំឲ្យធ្វើការវាយតម្លៃឡើងវិញពីស្ថានភាពរបស់ លោក ស សារិន ពិតជាមិនមាន មូលដ្ឋានត្រឹមត្រូវឡើយ។

១៩. **ផ្អែកតាមសំអាងហេតុនេះ** មេធាវីការពារក្ដី លោក ខៀវ សំផន សូមស្នើឲ្យអង្គជំនុំជម្រះមេត្តា៖

- **សម្រេច**ថាសំណើរបស់សហព្រះរាជអាជ្ញាដែលស្នើសុំឲ្យមានការវាយតម្លៃឡើងវិញពីហានិភ័យ ដែលដើមបណ្ដឹងរដ្ឋប្បវេណី លោក ស សារិន ត្រូវប្រឈម និងពីតម្រូវការរបស់គាត់សម្រាប់ វិធានការការពារ ពិតជាមិនមានមូលហេតុសមស្រប។
- **បដិសេធ**សំណើរបស់សហព្រះរាជអាជ្ញាដែលស្នើសុំឲ្យកោះហៅដើមបណ្ដឹងរដ្ឋប្បវេណីលោក ស សារិន មកសាជាថ្មី។

[25] ដូចយោងខាងលើ ទំព័រ ៥១-៥២។

| | | | |
|---|---|---|---|
| | មេធាវី គង់ សំអុន<br><br>មេធាវី Anta GUISSÉ<br><br>មេធាវី Arthur VERCKEN<br><br>មេធាវី Jacques VERGÈS | ភ្នំពេញ<br><br>ភ្នំពេញ<br><br>ប៉ារីស<br><br>ប៉ារីស | |
| កាលបរិច្ឆេទ | ឈ្មោះ | ទីកន្លែង | ហត្ថលេខា |